# ការលើកកម្ពស់ពាណិជ្ជកម្មដើម្បីកំណើនសេដ្ឋកិច្ចនៅកម្ពុជា[១]

## សេចក្តីផ្តើម

គ្មានប្រទេសណាអាចរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ បានយូរអង្វែង ដោយមិនធ្វើការពង្រីកពាណិជ្ជកម្មឡើយ។ ការបើកចំហចំពោះពាណិជ្ជកម្ម វាជះឥទ្ធិពលទៅលើកំណើនតាមបែបបទជាច្រើន៖ ១) វាធ្វើឲ្យប្រទេសនោះអាចទាញផលចំណេញពីឧត្តមភាពប្រៀបធៀប និងបង្កើនប្រសិទ្ធភាពនៃការបែងចែកធនធាន ២) វាសម្រួលដល់ការទទួលយកចំណេះដឹង និងបច្ចេកវិជ្ជាពីបរទេស ដែលនឹងជួយបង្កើនផលិតភាព និង ៣) ទាក់ទាញវិនិយោគបានកាន់តែច្រើន ជំរុញការប្រកួតប្រជែង និងកែលំអសមត្ថភាពប្រកួតប្រជែង។ កម្ពុជាបានអនុវត្តតាមគន្លងកំណើននេះ ក្នុងពេលសេដ្ឋកិច្ចកំពុងស្ទុះឡើងក្នុងប៉ុន្មានទសវត្សរ៍កន្លងទៅ ដោយមានការផ្លាស់ប្តូរដ៏សំខាន់ពី របបពាណិជ្ជកម្មគ្រប់គ្រងជាក់ស្តែងដោយរដ្ឋ ទៅជា របបពាណិជ្ជកម្មតម្រង់ទិសទៅទីផ្សារខាងក្រៅ។ នៅពេលបច្ចុប្បន្នដែលវិស័យពាណិជ្ជកម្មបានក្លាយជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិនោះ បញ្ហាប្រឈមធំគឺ តើត្រូវធ្វើដូចម្តេចដើម្បីឲ្យពាណិជ្ជកម្មជួយជំរុញកំណើនសេដ្ឋកិច្ច។ អត្ថបទនេះព្យាយាមឆ្លើយនឹងសំនួរសំខាន់ពីរ៖ ១) ហេតុអ្វីពាណិជ្ជកម្មសំខាន់ជាខ្លាំងចំពោះគន្លងកំណើនសេដ្ឋកិច្ចនៅកម្ពុជា? ២) តើត្រូវមានគោលនយោបាយអ្វីខ្លះ ដើម្បីឲ្យពាណិជ្ជកម្មជួយជំរុញកំណើនសេដ្ឋកិច្ចនៅកម្ពុជា?

## ហេតុអ្វីពាណិជ្ជកម្មសំខាន់ជាខ្លាំង ចំពោះគន្លងកំណើនសេដ្ឋកិច្ចនៅកម្ពុជា?

ពាណិជ្ជកម្ម និងគោលនយោបាយពាណិជ្ជកម្ម សំខាន់ជាខ្លាំងចំពោះគន្លងកំណើនសេដ្ឋកិច្ចនៅកម្ពុជា ដោយសារហេតុផលធំៗ ៣ គឺ៖ ១) ការផ្លាស់ប្តូរក្នុងគោលនយោបាយពាណិជ្ជកម្ម បានបង្កើតនូវលក្ខខណ្ឌអំណោយផលសម្រាប់យុទ្ធសាស្ត្រពាណិជ្ជកម្មបន្តទៅមុខទៀត ២) ពាណិជ្ជកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរីកលូតលាស់នាពេលកន្លងមក និង ៣) ទិដ្ឋភាពនៃពាណិជ្ជកម្មអន្តរជាតិកំពុងផ្លាស់ប្តូរលឿនណាស់ ដែលទាមទារឲ្យមានការកែសម្រួលផ្នែកគោលនយោបាយជាប្រចាំ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនៃសាកលភាវូបនីយកម្ម។

## *ឥទ្ធិពលល្អនៃការវិវត្តក្នុងពេលកន្លងមក*

### *ការផ្លាស់ប្តូរគោលនយោបាយពាណិជ្ជកម្មប្រកបដោយជោគជ័យ*

កម្ពុជា បានធ្វើការផ្លាស់ប្តូរប្រកបដោយជោគជ័យពីសេដ្ឋកិច្ចបែបផែនការប្រមូលផ្តុំ ទៅជាសេដ្ឋកិច្ចបែបទីផ្សារ ដោយបានបោះបង់នូវរបបសេដ្ឋកិច្ចមួយ ដែលរដ្ឋជាអ្នកត្រួតត្រាយ៉ាងតឹងរ៉ឹងទៅលើថ្លៃ និងបរិមាណទំនិញដែលត្រូវផលិត នាំចូល និងនាំចេញ ហើយមកចាប់អនុវត្តនូវយុទ្ធសាស្ត្រពាណិជ្ជកម្មមួយ ដែលតម្រង់ទិសទៅទីផ្សារខាងក្រៅ។ កំណែទម្រង់បន្ទាន់ៗបំផុតមួយចំនួនមានដូចជា ការលុបចោលនូវការគ្រប់គ្រងផ្តាច់មុខរបស់រដ្ឋទៅលើពាណិជ្ជកម្មក្រៅប្រទេស ការប្រកាសឲ្យប្រើច្បាប់វិនិយោគបរទេសដែលអនុញ្ញាតឲ្យក្រុមហ៊ុនឯកជន ចូលរួមក្នុងពាណិជ្ជកម្មក្រៅប្រទេស ការលុបចោលនូវការគ្រប់គ្រងលើថ្លៃទំនិញ ការលុបបំបាត់នូវការដាក់កំហិតផ្នែកបរិមាណ យុទ្ធនាការកសាងទំនាក់ទំនងជាមួយដៃគូពាណិជ្ជកម្មធំៗ និងសមាជិកភាពក្នុងប្រព័ន្ធពាណិជ្ជកម្មក្នុងតំបន់និងពហុភាគី។ ជាលទ្ធផល សេដ្ឋកិច្ចកម្ពុជាកាន់តែបើកទូលាយ និងមានសមាហរណកម្មកាន់តែខ្លាំង ហើយគោលនយោបាយពាណិជ្ជកម្ម ត្រូវបានកែតម្រឹមឲ្យស៊ីគ្នាទៅនឹងវិធាន និងច្បាប់ពាណិជ្ជកម្មអន្តរជាតិ។ យុទ្ធសាស្ត្រទាំងនេះបានក្លាយជាមូលដ្ឋានដ៏សមស្រប សម្រាប់កំណែទម្រង់គោលនយោបាយជាបន្តទៀត និងពង្រឹងទំនុកចិត្តនៃវិស័យសាធារណៈ និងឯកជន ទៅលើការគ្រប់គ្រងដំណើរការកំណែទម្រង់របស់រដ្ឋាភិបាល។

### *លក្ខខណ្ឌសេដ្ឋកិច្ចអំណោយផលសម្រេចបានតាមរយៈកំណែទម្រង់ពីមុន*

កន្លងមក កម្ពុជាអនុវត្តបានយ៉ាងល្អក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ អតិផរណាអាចរក្សាបានឲ្យនៅក្រោមកម្រិត ៥% អត្រាប្តូរប្រាក់រៀលទល់នឹងដុល្លារមានស្ថិរភាពល្អ ហើយទំនុកចិត្តខាងផ្នែកហិរញ្ញវត្ថុក៏កាន់តែរឹងមាំឡើង។ វិស័យហិរញ្ញវត្ថុបានរីកចម្រើនគួរឲ្យកោតសរសើរ ទាំងនៅក្នុងបរិយាកាសអាជីវកម្ម គំនិតគិតគូរបែបថ្មី និងការប្រកួតប្រជែង។

បរិយាកាសធ្វើអាជីវកម្ម និងវិនិយោគ បានល្អប្រសើរឡើងគួរឲ្យកត់សម្គាល់។ រយៈពេលត្រៀមរៀបចំសម្រាប់ការនាំចេញបានថយចុះពី ៤៣ថ្ងៃ នៅឆ្នាំ២០០៦ មកត្រឹម ២២ថ្ងៃ នៅឆ្នាំ២០១១ ហើយរយៈពេលត្រៀមរៀបចំសម្រាប់ការនាំចូលបានថយចុះពី ៥៣ថ្ងៃ មកត្រឹម ២៦ថ្ងៃ (World Bank 2013)។ តាមការចាប់អនុវត្តប្រើប្រព័ន្ធទិន្នន័យគយស្វ័យប្រវត្តិ (ASYCUDA) លិខិតប្រកាសការនាំចូលជាង ៩០% អាចដោះស្រាយបានក្នុងរយៈពេល ២៤ម៉ោង (គិតចាប់ពីការដាក់លិខិតប្រកាសទំនិញដល់ការបញ្ចេញទំនិញ) (WTO 2011)។ លើសពីនេះទៀត ការធ្វើអង្កេតមួយនៅកម្រិតក្រុមហ៊ុននៅកម្ពុជា បានបង្ហាញនូវការយល់ឃើញប្រសើរជាងមុនអំពីបរិយាកាសធ្វើវិនិយោគ ជាពិសេសទាក់ទងនឹងកំណែទម្រង់ផ្នែកច្បាប់ និងលទ្ធភាពក្នុងការប្រើប្រាស់ហិរញ្ញវត្ថុ និងការធ្វើពាណិជ្ជកម្ម។ ទោះបីនៅមានការងារត្រូវធ្វើជាច្រើនទៀត ដើម្បីបង្កើតបរិយាកាសវិនិយោគអំណោយផលដល់ការចាប់ផ្តើម និងកិច្ចដំណើរការអាជីវកម្មក្តី ក៏បរិយាកាសនាបច្ចុប្បន្នមានផ្តល់នូវលក្ខខណ្ឌដ៏ចាំបាច់ៗ សម្រាប់ការធ្វើវិនិយោគពាណិជ្ជកម្ម និងកំណើនកម្រិតខ្ពស់។

---

[១] រៀបរៀងដោយលោក ហ៊ីង វុត្ថា អ្នកស្រាវជ្រាវក្នុង កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI។

*តួអង្គសកម្មនៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការក្នុងតំបន់*

កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុង មហាអនុតំបន់មេគង្គ (GMS) យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច តំបន់ Ayeyawady-Chao Phrayay-មេគង្គ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)និងគ្រោងការផ្តួចផ្តើមដោយអាស៊ានមួយចំនួនទៀត ដូចជា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន និងគំនិតផ្តួចផ្តើមអាស៊ានបូកបី។

ការផ្តួចផ្តើមធ្វើសហប្រតិបត្តិការក្នុងតំបន់ ផ្តល់អត្ថប្រយោជន៍ច្រើនបែបយ៉ាងដល់កម្ពុជា។ កម្ពុជាទទួលបានប្រយោជន៍ពីគម្រោងការតភ្ជាប់ និងហេដ្ឋារចនាសម្ព័ន្ធ GMS និងអាស៊ាន ក្នុងរូបភាពជា ផ្លូវថ្នល់សំខាន់ៗ ផ្លូវដែក ស្ពាន ផ្លូវទឹក និងកំពង់ផែ។ ទន្ទឹមគ្នានឹងការរីកលូតលាស់ហេដ្ឋារចនាសម្ព័ន្ធរឹងទាំងនេះ ក៏មានការជឿនលឿនក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធទន់ដែរ៖ កំណែទម្រង់បទបញ្ញត្តិរបស់ស្ថាប័នរដ្ឋាភិបាល និងការកសាងសមត្ថភាពមន្ត្រីទទួលខុសត្រូវធ្វើឲ្យចលនាទំនិញ និងមនុស្សឆ្លងកាត់ព្រំដែន មានភាពរលូន តម្លាភាព និងប្រសិទ្ធភាពផ្នែកចំណាយ។ សេដ្ឋកិច្ចក៏បានបើកទូលាយជាងមុនដែរ។ ឧទាហរណ៍ នៅក្រោមគម្រោងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន កម្ពុជាបានប្តេជ្ញាចិត្តកាត់បន្ថយជាបណ្តើរៗនូវ ពន្ធស្ទើរតែទាំងអស់លើទំនិញនាំចូលពីសមាជិកអាស៊ាន ឲ្យមកនៅក្នុងចន្លោះពី 0% និង ៥% នៅត្រឹមឆ្នាំ ២០១០។ នៅក្រោមគម្រោងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន កម្ពុជាត្រូវលុបបំបាត់ពន្ធគយទាំងអស់ នៅត្រឹមថ្ងៃទី១ មករា ២០១៥។

សមាជិកភាពក្នុងក្របខ័ណ្ឌផ្សេងៗនៃ ពាណិជ្ជកម្មក្នុងតំបន់ ផ្តល់ឲ្យកម្ពុជានូវបទពិសោធន៍អំពីកិច្ចសហប្រតិបត្តិការក្នុងតំបន់។ កម្ពុជាកំពុងរៀនសូត្រដោយអនុវត្តផ្ទាល់លើកិច្ចការពាណិជ្ជកម្មអន្តរជាតិ និងដំណើរការកែទម្រង់ក្នុងស្រុក ហើយសំខាន់បំផុត គឺកំពុងបង្កើតគោលនយោបាយក្រៅប្រទេសធ្វើសហប្រតិបត្តិការប្រកបដោយមិត្តភាព ដើម្បីលើកកម្ពស់កេរ្តិ៍ឈ្មោះរបស់ខ្លួននៅក្នុងតំបន់ និងពិភពលោក។

*កំណើនកម្រិតពាណិជ្ជកម្ម និងការប្រកួតប្រជែង*

ចាប់ពីពាក់កណ្តាលទសវត្សរ៍១៩៩០ មក ការរីកលូតលាស់ឡើងវិញយ៉ាងឆាប់រហ័សនៃវិស័យពាណិជ្ជកម្ម បានក្លាយជាកម្លាំងជំរុញមួយដ៏សំខាន់នៃកំណើនសេដ្ឋកិច្ច។ ពាណិជ្ជកម្មសរុបនៅឆ្នាំ២០១១ ស្ទុះឡើងយ៉ាងខ្លាំងដល់ ១២,១៦ពាន់លានដុល្លារ ធៀបនឹង ៣,៣៣ពាន់លានដុល្លារ នៅឆ្នាំ២000 ឬមានអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ១៤%។ ការវិភាគលើសន្ទស្សន៍ឧត្តមភាពប្រៀបធៀប (RCA) បង្ហាញថា កម្ពុជាមានឧត្តមភាពខ្លាំងក្នុងការប្រកួតប្រជែងលើផ្នែកផលិតកម្មអតិពលកម្ម ដូចជា សម្លៀកបំពាក់ (HS[២] 61, 62, 63) និង ស្បែកជើង (HS 64) ហើយការនាំចេញផលិតផលទាំងនេះមានទំហំជិតដល់ ២/៣ នៃការនាំចេញសរុប។ ទោះជាតម្រូវការសម្លៀកបំពាក់ និងស្បែកជើងបានធ្លាក់ចុះនៅទីផ្សារនាំចេញសំខាន់ៗក្តី ក៏ផលិតកម្មទំនិញទាំងនេះនឹងបន្តកើនឡើង ជាពិសេសក្នុងអនាគតដ៏ខ្លីខាងមុខ ហើយលក្ខណៈប្រកួតប្រជែងនៃទំនិញនេះនៅតែខ្លាំងក្លាដដែល។

កម្ពុជា មិនទាន់អាចប្រកួតប្រជែងក្នុងផ្នែកពាណិជ្ជកម្មកសិកម្មបានទេ ហើយផលិតផលកសិកម្មរួមចំណែកតែ ៤,៩% នៃការនាំចេញសរុបប៉ុណ្ណោះ ប៉ុន្តែមានការព្យាករណ៍ពីនិន្នាការវិជ្ជមានក្នុងផ្នែកនេះ។ សន្ទស្សន៍ RCA ផ្តល់នូវការប្រមើលឃើញលើផលិតផលកសិកម្មមួយចំនួន។ ផលិតផលខ្លះដែលមិនមានឧត្តមភាពប្រៀបធៀបកាលពីបួនឆ្នាំមុន ឥឡូវនេះហាក់ដូចកើនលក្ខណៈប្រកួតប្រជែង និងរួមចំណែកកាន់តែច្រើនក្នុងការនាំចេញសរុប។ គ្រាប់ធញ្ញជាតិជាផលិតផលមានជោគជ័យខ្លាំងជាងគេទាំងនៅក្នុងកំណើនតម្លៃនាំចេញ និងភាពប្រកួតប្រជែង ដូចអាចមើលឃើញតាមកំណើនគួរឲ្យកត់សម្គាល់ក្នុងសន្ទស្សន៍ RCA ពី 0,៤ពិន្ទុ នៅឆ្នាំ២00៧ ដល់ ៤,៤ពិន្ទុ នៅឆ្នាំ២0១១។ ផលិតផលនាំចេញចម្បងៗផ្សេងទៀត ដែលមានកំណើនឧត្តមភាពប្រៀបធៀបខ្លាំងដែរ រួមមាន ស្ករ នំធ្វើពីស្ករ សត្វរស់ កៅស៊ូ និងបន្លែ និងមើមឈើអាចបរិភោគបាន។

### ***តួនាទីពាណិជ្ជកម្មក្នុងដំណើរពីអតីតកាលនៃកំណើន***

ទោះបីមិនមានភស្តុតាងជាក់ស្តែងក៏ដោយ ក៏គេពិបាកនឹងបដិសេធពីតួនាទីដ៏សំខាន់នៃគោលនយោបាយពាណិជ្ជកម្ម ក្នុងការជំរុញកំណើនដែរ។ កម្ពុជាទទួលបានអត្ថប្រយោជន៍ច្រើនពីគោលនយោបាយវិនិយោគ និងពាណិជ្ជកម្មសេរីរបស់ខ្លួន រាប់ទាំង ការតភ្ជាប់សេដ្ឋកិច្ចកាន់តែរឹងមាំទៅនឹងទីផ្សារក្នុងតំបន់និងសាកលលោក ហើយនិង កំណើនពាណិជ្ជកម្ម ការវិនិយោគ និងការប្រកួតប្រជែង។ កំណើនភាគច្រើនកើតចេញពីវិស័យ ៤ គឺ កាត់ដេរសម្លៀកបំពាក់និងស្បែកជើង ទេសចរណ៍ សំណង់ និងកសិកម្ម។ កំណើនខ្លាំងក្នុងវិស័យកាត់ដេរ ជាឧទាហរណ៍បង្ហាញយ៉ាងច្បាស់ពី បែបបទដែលគោលនយោបាយពាណិជ្ជកម្មតម្រង់ទិសទៅខាងក្រៅវាជះឥទ្ធិពលទៅលើកំណើន។ វិស័យទេសចរណ៍សម្រេចបានកំណើនលឿន ដោយផ្អែកលើគោលនយោបាយសំខាន់ៗ ដូចជា គោលនយោបាយបើកចំហជើងមេឃ ដែលដាក់អនុវត្តចុងឆ្នាំ១៩៩៧ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់លើគោលនយោបាយ ឈ្មោះថា យុទ្ធសាស្ត្រទេសចរណ៍ក្នុងមហាអនុតំបន់មេគង្គ ដែលសំដៅបង្កើតវិស័យទេសចរណ៍អនុតំបន់មួយឲ្យដើរតួជាក្បាលម៉ាស៊ីនសម្រាប់ការអភិវឌ្ឍ ឬនិងផែនការយុទ្ធសាស្ត្រអាស៊ាន។ សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ ជាពិសេស ក្រោមក្របខ័ណ្ឌប្រព័ន្ធពាណិជ្ជកម្មកសិកម្មពិភពលោក (GATS) បានជួយពង្រឹងដល់ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា (Hing 2009)។ ដែនគ្របដណ្តប់នៃប្រព័ន្ធហិរញ្ញវត្ថុបានរីកធំ និងរឹងមាំឡើង ហើយលក្ខណៈប្រកួតប្រជែង និងប្រសិទ្ធភាពរបស់វា ក៏បានល្អប្រសើរឡើងគួរឲ្យកត់សម្គាល់។

[២] ប្រព័ន្ធដាក់លេខកូដ និងធ្វើសុខដុមនីយកម្មមុខទំនិញ (HS) នៃតារាងពន្ធគយ។

### *ការប្រែប្រួលទិដ្ឋភាពពាណិជ្ជកម្ម*

អភិបាលកិច្ចពាណិជ្ជកម្មអន្តរជាតិ មានការប្រែប្រួលគួរឲ្យកត់សម្គាល់។ ពិភពលោកកាន់តែមានការតភ្ជាប់គ្នាខ្លាំងឡើងៈ ពាណិជ្ជកម្មពហុភាគីដែលគាំទ្រដោយច្បាប់នានារបស់ អង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅតែជាសសរស្តម្ភនៃប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិ, របៀបរបបពាណិជ្ជកម្មក្នុងតំបន់ (RTAs) បានកើនស្មុគស្មាញដែលអាចជំពាក់គ្នាស្មុគស្មាញដូច "មីមួយចាន" (spaghetti bowl) ហើយខ្សែចង្វាក់ផ្គត់ផ្គង់ជាសាកលកើតមានកាន់តែច្រើនឡើង។ បទពិសោធន៍ពិភពលោកបង្ហាញថា មិនមានប្រទេសណាមួយ អាចរក្សាកំណើនខ្ពស់បានយូរអង្វែង ដោយមិនធ្វើសមាហរណកម្មទៅក្នុង សេដ្ឋកិច្ចពិភពលោកនោះទេ ហើយវាគួរតែជាមធ្យោបាយសម្រាប់ឈានទៅមុខ នៃយុទ្ធសាស្ត្រកំណើន និងពាណិជ្ជកម្មរបស់កម្ពុជា ផងដែរ។

ការរំពឹងទុកអំពី ទីផ្សារនិងប្រព័ន្ធផលិតកម្មអាស៊ីធ្វើសមាហរណកម្មបញ្ចូលគ្នាចាប់ពីចិនភាគខាងត្បូង កាត់តាមប្រទេស GMS ទៅកាន់ប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ បានផ្តល់ឲ្យកម្ពុជានូវការតភ្ជាប់ទំនាក់ទំនងយ៉ាងល្អនៃវិនិយោគ និងពាណិជ្ជកម្ម ដើម្បីជំរុញវិបុលភាព និងការអភិវឌ្ឍវិស័យឯកជន។ កន្លងមក កម្ពុជាមិនទាន់បានក្លាយជាផ្នែកមួយនៃប្រព័ន្ធចែករំលែកផលិតកម្មដ៏មានសន្ទុះក្នុងតំបន់នោះទេ ប៉ុន្តែការប្រែប្រួលថ្មីមួយនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ជាសាកលរបស់តំបន់អាស៊ី ទំនងជាការចាប់ផ្តើមសម័យថ្មីមួយពោរពេញដោយឱកាសល្អ សម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចកំពុងស្ទុះឡើង។ កំណើនបន្ទុកចំណាយ បានជំរុញឲ្យក្រុមហ៊ុនច្រើនណាស់ផ្លាស់ទីតាំងផលិតកម្មចេញពីប្រទេសចិន ទៅកាន់ប្រទេសមានបន្ទុកចំណាយទាបជាង ដើម្បីទាញយកអត្ថប្រយោជន៍ពីឧត្តមភាពប្រៀបធៀបពោលគឺ ថ្លៃពលកម្មទាប កំណើនភាពពឹងផ្អែកគ្នាក្នុងតំបន់ និងលទ្ធភាពចូលទៅកាន់ទីផ្សារប្រទេសទី៣។ និន្នាការនេះ អាចមើលឃើញយ៉ាងច្បាស់នៅក្នុង វិនិយោគរបស់ក្រុមហ៊ុនជប៉ុនពីរ គឺ Minebea ដែលជាក្រុមហ៊ុននាំមុខគេក្នុងពិភពលោកខាងការផលិតគ្រឿងម៉ាស៊ីនតូចៗ និង Sumitomo Electric ជាក្រុមហ៊ុននាំមុខគេខាង ការផលិតបណ្តាញខ្សែអគ្គិសនីគ្រឿងយន្ត ដែលបានបង្កើតកន្លែងផលិតកម្មដ៏ទំនើបនៅកម្ពុជា ដើម្បីបម្រើទីផ្សារសាកល។ ដោយសារខ្សែចង្វាក់ផ្គត់ផ្គង់សាកលត្រូវពឹងផ្អែកលើប្រព័ន្ធពាណិជ្ជកម្មបើកចំហ ហេតុនេះគោលនយោបាយឧស្សាហកម្ម និងពាណិជ្ជកម្ម ដើរតួនាទីសំខាន់ណាស់ក្នុងការកំណត់អត្រាដែលក្រុមហ៊ុនបរទេសមកបើកសាខានៅកម្ពុជា។

### អាទិភាពគោលនយោបាយសម្រាប់ពាណិជ្ជកម្មអន្តរជាតិ និងកំណើនសេដ្ឋកិច្ច

អត្ថបទនេះឯកភាពតាមមតិថា ពាណិជ្ជកម្មជាលក្ខខណ្ឌចាំបាច់មួយសម្រាប់កំណើនសេដ្ឋកិច្ច ប៉ុន្តែពាណិជ្ជកម្មតែមួយមុខមិនទាន់គ្រប់គ្រាន់ទេ។ ដើម្បីរក្សាកំណើនក្នុងរយៈពេលវែង ត្រូវមានកត្តារួមផ្សំជាច្រើនទៀត ក្រៅពីគោលនយោបាយជម្រុញការនាំចេញ ដូចជា រដ្ឋាភិបាលមានសមត្ថភាព ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការផ្ទេរចំណេះដឹងនិងបច្ចេកវិទ្យា និងការវិនិយោគកម្រិតខ្ពស់ក្នុងហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងការថែទាំសុខភាព។ ខាងក្រោមនេះ ជាអាទិភាពគោលនយោបាយ ដើម្បីជម្រុញការនាំចេញ និងលើកកម្ពស់ពិពិធកម្ម ដែលជាគន្លឹះសម្រាប់កំណើនសេដ្ឋកិច្ចមានចីរភាព។

*រក្សាការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចបានល្អៈ* ការធានាឲ្យបរិយាកាសម៉ាក្រូសេដ្ឋកិច្ចធន់នឹងវិបត្តិ និងមានស្ថិរភាព នៅតែជាគន្លឹះដ៏សំខាន់ញ៉ាំងឲ្យគោលនយោបាយជំរុញពាណិជ្ជកម្មសម្រេចជោគជ័យ។ អាទិភាពគោលនយោបាយដើម្បីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចបានល្អ រួមមាន ការរក្សាអតិផរណាឲ្យនៅក្រោម ៥% ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ការកសាងភាពធន់ទៅនឹងកត្តាខាងក្រៅ ការកែលំអការប្រមូលចំណូល និងការពង្រឹងសេវាកម្មវិស័យហិរញ្ញវត្ថុ។

*កែលំអបរិយាកាសវិនិយោគៈ* បរិយាកាសអំណោយផលដល់វិនិយោគ មានកត្តារួមផ្សំជាច្រើន ដូចជា កម្រិតប្រាកដប្រជានៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច, គុណភាព និងភាពងាយស្រួលប្រើប្រាស់នៃហេដ្ឋារចនាសម្ព័ន្ធ, វិសាលភាពបទបញ្ញត្តិរដ្ឋាភិបាល, លក្ខណៈនៃការយកពន្ធ, ចំណាយ និងលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុន, លទ្ធភាពបានប្រើប្រាស់ គុណភាព និងតម្លៃនៃកត្តាផលិតកម្ម, លក្ខណៈស្មើភាពគ្នាផ្តល់ឲ្យដោយរដ្ឋាភិបាលចំពោះក្រុមហ៊ុននានា, អភិបាលកិច្ច និងអំពើពុករលួយ, និងសន្តិសុខ។ អាទិភាពគោលនយោបាយជាបន្ទាន់ដើម្បីកែលំអចំណុចខ្សោយនៃបរិយាកាសវិនិយោគ រួមមាន ការកែលំអហេដ្ឋារចនាសម្ព័ន្ធ ការតម្រឹមនីតិវិធីគយ ការបង្កើនប្រសិទ្ធភាពផ្នែកភស្តុភារ និង ការវិនិយោគលើមូលធនមនុស្ស។

*សម្រួលនីតិវិធីពន្ធគយៈ* ទម្រង់បែបបទពន្ធគយ ដែលរួមមាន ការងារក្រដាសស្នាម ការពិនិត្យយល់ព្រម បទបញ្ញត្តិ និងប្រាក់កម្រៃ ជាឧបសគ្គចម្បងបំផុតបីដែលរារាំងដល់ការនាំចេញ (World Bank 2009; ADB 2012)។ ដំណើរការនាំចូល និងនាំចេញមិនមានប្រសិទ្ធភាពនេះ វាជះឥទ្ធិពលដោយផ្ទាល់ដល់ចំណាយពាណិជ្ជកម្មផលិតភាពកត្តាផលិតកម្មសរុបនិងការប្រកួតប្រជែង។ កម្ពុជា ត្រូវធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយនានា ដើម្បីជួយសម្រួលលើឧបសគ្គចម្បងៗចំពោះវិស័យឯកជន ជាពិសេសក្នុងដំណើរការជម្រះឯកសារគយនិងពាណិជ្ជកម្ម ការសម្របសម្រួលក្នុងចំណោមស្ថាប័នជួយសម្រួលផ្នែកពាណិជ្ជកម្ម និងលទ្ធភាពទទួលបានព័ត៌មានស្តីពី នីតិវិធីនាំចេញ បទបញ្ញត្តិ និងប្រាក់កម្រៃផ្សេងៗ។

*លើកកម្ពស់ប្រសិទ្ធភាពផ្នែកភស្តុភារៈ* កម្ពុជាស្ថិតក្នុងចំណោមប្រទេស មានសេវាកម្មភស្តុភារខ្វះប្រសិទ្ធភាពបំផុតនៅក្នុងតំបន់។ ការបំពេញមុខងារផ្នែកភស្តុភារមិនបានល្អ បណ្តាលមកពីកត្តាជាច្រើន មានជាអាទិ៍ គុណភាពអន់និងកង្វះហេដ្ឋារចនាសម្ព័ន្ធ ប្រសិទ្ធភាពនិងប្រសិទ្ធផលទាបក្នុងដំណើរការជម្រះឯកសារអនុវត្តដោយមន្ត្រីគយ និងភ្នាក់ងារត្រួតពិនិត្យនៅច្រកព្រំដែន ព្រមទាំងសមត្ថភាពនិងគុណភាពទាបនៃសេវាភស្តុភារ។ អន្តរាគមន៍គោលនយោបាយ អាចមានតាំងពីការកែលំអហេដ្ឋារចនាសម្ព័ន្ធរឹង ពាក់ព័ន្ធនឹងផ្នែកពាណិជ្ជកម្ម រហូតដល់ការលើកកម្ពស់ការគ្រប់គ្រងព្រំដែន ដែលមានជាអាទិ៍ កំណែ

ទម្រង់និងទំនើបកម្មបែបបទគយ ការចែកចាយព័ត៌មានធំទូលាយជាងមុន ការលើកកម្ពស់ភាពប្រកួតប្រជែងក្នុងសេវាដឹកជញ្ជូនទំនិញតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស និងលទ្ធភាពទទួលបានភ្លាមៗ នូវព័ត៌មានស្ដីពីកិច្ចព្រមព្រៀងដឹកទំនិញឆ្លងកាត់ព្រំដែន។

*ពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងតំបន់៖* កម្ពុជានៅមិនទាន់ទាញប្រយោជន៍បានពេញលេញពី ឱកាសល្អនានាផុសចេញពីការធ្វើសមាហរណកម្មក្នុងតំបន់នោះទេ (ឯកសារបោះពុម្ពផ្សាយរបស់ CDRI នាពេលខាងមុខ)។ បញ្ហាប្រឈមចំពោះមុខ គឺការធានាឲ្យវិស័យពាណិជ្ជកម្មអាចទទួលបាន និងទាញយកចំណេញពីកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីឲ្យការនាំចេញអាចមានចម្រុះមុខ លែងពឹងផ្អែកតែលើវិស័យមួយចំនួនតូច។ កម្ពុជាត្រូវពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីសម្រេចនូវចំណុចខាងលើ ព្រមទាំងគោលដៅអភិវឌ្ឍន៍ក្នុងរយៈពេលវែង។ ចំណុចសំខាន់បំផុតនៅក្នុងនេះ គឺការសម្របសម្រួល និងការបន្សីចង្វាក់គ្នារវាង កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍GMS-អាស៊ាន-អាស៊ីបូព៌ា និងសមាហរណកម្មក្នុងតំបន់ ដើម្បីញ៉ាំងឲ្យមានការយកចិត្តទុកដាក់លើ កំណើនយូរអង្វែង និងការភ្ជិតគំលាតផ្នែកអភិវឌ្ឍន៍ ដោយមានការធ្វើវិនិយោគក្នុងតំបន់ទៅលើការអភិវឌ្ឍសមត្ថភាពស្ថាប័នក្នុងរយៈពេលវែង។

*ពង្រឹងប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស (SEZ)៖* SEZs ត្រូវបានបង្កើតឡើងជិតមួយទស្សវត្សរ៍មកហើយ ប៉ុន្តែមិនទាន់បានជោគជ័យដូចការរំពឹងទុក ក្នុងការទាក់ទាញវិនិយោគិននោះទេ។ ក្នុងចំណោម SEZs បានទទួលការអនុម័តទាំង ២១ មានត្រឹមតែ ៨ប៉ុណ្ណោះ ដែលមានដំណើរការ។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធមានគុណភាពខ្ពស់ និងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុនោះ SEZs ត្រូវគ្រប់គ្រងពន្ធ និងពង្រឹងអនុវត្តន៍បទបញ្ញត្តិឲ្យមានប្រសិទ្ធភាពនិងមានស្តង់ដារខ្ពស់ លុបបំបាត់ឧបសគ្គផ្នែកការិយាធិបតេយ្យនិងរដ្ឋបាល ស្វែងរកដំណោះស្រាយជួយសម្រួលបញ្ហាផ្សេងៗដែលវិនិយោគិនជួបប្រទះ បង្កើតទំនាក់ទំនងការងារឲ្យកាន់តែមានភាពបត់បែនល្អ និងធានាលទ្ធភាពរកបានជានិច្ច ទាំងកម្លាំងពលកម្មមានជំនាញខ្ពស់ និងមានជំនាញទាប។

*ធ្វើវិនិយោគក្នុងមូលធនមនុស្ស៖* ទីផ្សារពលកម្មកម្ពុជានាបច្ចុប្បន្ន មានលក្ខណៈសម្គាល់ដោយឡែកគឺ ចំនួនភាគច្រើននៃកម្លាំងពលកម្មមានកម្រិតអប់រំទាប មុខជំនាញពលករមិនស៊ីគ្នានឹងការងារ និងកង្វះខាតជំនាញតាមផ្នែកមួយចំនួន។ ពិនិត្យតាមបទពិសោធន៍ប្រទេសមានជោគជ័យក្នុងការនាំចេញ កម្ពុជាត្រូវធ្វើវិនិយោគច្រើនៗទៅលើការអភិវឌ្ឍមូលធនមនុស្ស។ គោលនយោបាយផ្នែកអប់រំ គួរសង្កត់ធ្ងន់លើការអប់រំថ្នាក់បឋមសិក្សាជាសាកល និងការកែលំអគុណភាពអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ការអប់រំថ្នាក់ឧត្តមសិក្សា គួរផ្ដោតលើការអប់រំជាន់ខ្ពស់ខាងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការអប់រំនិងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជម្រើសគោលនយោបាយជាអាទិភាព គួររួមមាន ការកែលំអហេដ្ឋារចនាសម្ព័ន្ធសាលារៀន ជាពិសេសនៅតំបន់ជនបទ ការបង្កើនចំនួនសាលាបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការនូវពលករមានជំនាញ ការលើកកម្ពស់គុណភាពការបង្រៀន និងអភិបាលកិច្ចនៃការអប់រំថ្នាក់ឧត្តមសិក្សា និងការដាក់បញ្ចូលជាផ្លូវការនូវសមត្ថភាពផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ទៅក្នុងស្ថាប័នអប់រំជាន់ខ្ពស់។

*កែលំអសេវាផ្ដល់ព័ត៌មានពីទីផ្សារនាំចេញ៖* វិស័យឯកជនខ្វះខាតចំណេះដឹងពីនីតិវិធីនាំចេញ និងទីផ្សារនាំចេញ (WTO 2011)។ ពិនិត្យតាមតួនាទីនៃបណ្ដាអង្គការជំរុញពាណិជ្ជកម្ម ក្នុងការលុបបំបាត់បញ្ហាទទួលបានព័ត៌មានមិនដូចគ្នានោះ ការពង្រឹងតួនាទីនៃនាយកដ្ឋានលើកកម្ពស់ពាណិជ្ជកម្ម (TPD) ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រជំរុញការនាំចេញ គឺជាសកម្មភាពដ៏ត្រឹមត្រូវ។ វិធានការជាអាទិភាពក្នុងរយៈពេលខ្លី គួរផ្ដោតលើការផ្ដល់ការគាំទ្រ និងព័ត៌មានដែលក្រុមហ៊ុននាំចេញត្រូវការ ជាពិសេសក្នុងការអភិវឌ្ឍផលិតផលនិងទីផ្សារ និងសេវាព័ត៌មានពីទីផ្សារ។ មូលនិធិបានពីដៃគូអភិវឌ្ឍន៍នានា អាចមានប្រយោជន៍ក្នុងដំណាក់កាលដំបូងនៃកំណែទម្រង់ ព្រោះវាអាចជួយជំរុញរបៀបរបបអនុវត្តល្អ និងការរៀបចំប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែការជួយទ្រទ្រង់បែបនេះគួរតែមានលក្ខណៈបណ្ដោះអាសន្ន ហើយត្រូវបន្តដំណើរការដោយប្រើធនធានក្នុងស្រុក តាមរយៈការផ្ដល់ថវិកាទាំងស្រុងពីរដ្ឋាភិបាល ឬការគួបផ្សំគ្នារវាងថវិកាពីរដ្ឋាភិបាល និងការបង់ថ្លៃសេវា។ សមាសធាតុសំខាន់មួយទៀតក្នុងការពង្រឹង TPD គឺការធានាគុណភាពបុគ្គលិកតាមរយៈការកសាងសមត្ថភាពជាប្រចាំ និងការជ្រើសរើសបុគ្គលិកមានទេពកោសល្យ និងបទពិសោធន៍ផ្នែកពាណិជ្ជកម្ម។ វិធានការផ្នែកគោលនយោបាយ គួរផ្ដោតផងដែរលើការកសាងបណ្ដាញពាណិជ្ជកម្មក្នុងស្រុក (រដ្ឋាភិបាល វិស័យឯកជន និងវិនិយោគិន) និងបណ្ដាញក្រៅប្រទេស (រដ្ឋាភិបាលបរទេស អ្នកទិញនិងវិនិយោគិនអន្តរជាតិ) និងការកែលំអប្រព័ន្ធផ្ដល់ព័ត៌មាន។

*ជំរុញការអនុវត្តតាមស្ដង់ដារ៖* កម្ពុជាបានជួបបញ្ហាប្រឈមធំៗណាស់ ក្នុងការអនុវត្តតាមស្ដង់ដារបច្ចេកទេសរបស់ប្រទេសនាំចូល។ ការត្រួតពិនិត្យ និងពង្រឹងអនុវត្តន៍តាមស្ដង់ដារ បានជួបឧបសគ្គធ្ងន់ធ្ងរ មានជាអាទិ ក្របខ័ណ្ឌច្បាប់និងបទបញ្ញត្តិអន់ខ្សោយ កង្វះការសម្របសម្រួល និងការជាន់តួនាទីគ្នាក្នុងចំណោមទីភ្នាក់ងារផ្សេងៗ អវត្តមានការធ្វើតេស្ដជាប្រព័ន្ធក្នុងមន្ទីរពិសោធន៍ ដើម្បីជួយទ្រទ្រង់ដល់ការត្រួតពិនិត្យ ដោយសារធនធានមនុស្សនិងហិរញ្ញវត្ថុមានតិច កង្វះការពិនិត្យតាមដាន និងអធិការកិច្ចជាលក្ខណៈប្រព័ន្ធ និងប្រព័ន្ធចេញលិខិតបញ្ជាក់ដោយមិនមានការធ្វើតេស្ដផ្ទៀងផ្ទាត់ (FAO 2010)។ កំណែទម្រង់គ្រប់ជ្រុងជ្រោយនានាក៏ត្រូវធ្វើដែរ ដើម្បីដោះស្រាយបញ្ហាចម្បងៗនៅក្នុងប្រព័ន្ធគ្រប់គ្រងស្ដង់ដារ។ វិធានការជាក់ស្ដែងនានា គួរផ្ដោតលើការពង្រឹងក្របខ័ណ្ឌស្ថាប័ន ជាពិសេសទាក់ទងនឹង អាណត្តិ និងការសម្របសម្រួល, ការកសាងសមត្ថភាពផ្នែកគ្រប់គ្រង និងបច្ចេកទេស, និងការបង្កើតអង្គភាពវាយតម្លៃរបស់កម្ពុជា ដែលទទួលស្គាល់ដោយទីភ្នាក់ងារផ្ដល់ការទទួលស្គាល់ថ្នាក់អន្តរជាតិ។

## សេចក្តីបញ្ចប់

ថ្វីបើពាណិជ្ជកម្មជាលក្ខខណ្ឌចាំបាច់ សម្រាប់គន្លងកំណើនរបស់កម្ពុជាក្តី ប៉ុន្តែពាណិជ្ជកម្មតែមួយមុខមិនទាន់គ្រប់គ្រាន់ទេ។ គោលនយោបាយពាណិជ្ជកម្ម អាចជួយបង្កើនល្បឿនការធ្វើសមាហរណកម្មចូលទៅក្នុងសេដ្ឋកិច្ចពិភពលោក និងពង្រឹងយុទ្ធសាស្រ្តកំណើនដ៏ឈ្លាសវៃមួយ ប៉ុន្តែវាមិនអាចធានាឲ្យដំណើរការទាំងនេះពិតជាមានជោគជ័យនោះទេ។ នៅមានសមាសធាតុជាច្រើនទៀតដែលជួយកាត់បន្ថយឧបសគ្គរាំងកំណើន ដូចជាការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរ បរិយាកាសអំណោយផលសម្រាប់ពាណិជ្ជកម្មនិងវិនិយោគ ស្ថាប័នមានសមត្ថភាព និងការធ្វើវិនិយោគយ៉ាងត្រឹមត្រូវក្នុងមូលធនមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ។ កំណែទម្រង់បន្ថែម និង សេរីភាវូបនីយកម្មគោលនយោបាយពាណិជ្ជកម្ម ត្រូវតែមាន ឆន្ទៈនយោបាយពីថ្នាក់ដឹកនាំសន្ទុះដ៏ខ្លាំងនិងកម្លាំងជំរុញថ្មីៗពីអ្នកពាក់ព័ន្ធសំខាន់ៗ ហើយនិងរដ្ឋាភិបាលដែលមានសមត្ថភាពនិងទំនួលខុសត្រូវខ្ពស់។

## ឯកសារយោង


ADB–Asian Development Bank (2012), *Trade and Trade Facilitation in the Greater Mekong Subregion* (Manila: ADB)

CDRI–Cambodia Development Resource Institute (forthcoming), *ASEAN 2030: Growing Together for Economic Prosperity – The Challenges*, *the Cambodia Background Paper* (Phnom Penh: CDRI)

FAO–Food and Agriculture Organisation (2010), "An Action Plan to Improve SPS Capacity in Cambodia", STDF Project 246, http://www.standardsfacility.org/files/Project_documents/Project_Grants/STDF_246_Final_Report_Jul-10.pdf (accessed at 15 March 2013)

Hing Vutha (2009), "Trade Liberalisation in Financial Sector: Experience from Cambodia", final research paper, University of Barcelona, Spain

World Bank (2013), "Ease of doing Business in Cambodia", **http://www.doingbusiness.org/data/exploreeconomies/cambodia** (accessed on 15 March 2013)

WTO–World Trade Organisation (2011), *Trade Policy Review: Cambodia*, WT/TPR/S/253 (Geneva: WTO)



**ឯកសារពិភាក្សាចេញផ្សាយថ្មីៗនៅលើគេហទំព័រ** www.cdri.org.kh

**New Working Papers (WP) Online Publications at www.cdri.org.kh**

WP 70) Hing Vutha, Saing Chan Hang and Khieng Sothy (August 2012), *Baseline Survey for Socioeconomic Impact Assessment: Greater Mekong Sub-region Transmission Project*

71) Kim Sedara and Joakim Öjendal with Chhoun Nareth and Ly Tem (December 2012), *A Gendered Analysis of Decentralisation Reform in Cambodia*

72) Hem Socheth (March 2013), *Impact of the Global Financial Crisis on Cambodian Economy at Macro and Sectoral Levels*

73) Hay Sovuthea (March 2013), *Government Response to Inflation Crisis and Global Financial Crisis*

74) Ngin Chanrith (March 2013), *Impact of the Global Financial Crisis on Employment in SMEs in Cambodia*

75) Tong Kimsun (March 2013), *Impact of the Global Financial Crisis on Poverty: Evidence from Nine Villages in Cambodia*

76) Hing Vutha (March 2013), *Impact of the Global Financial Crisis on the Rural Labour Market: Evidence from Nine Villages in Cambodia*

77) Saing Chan Hang (March 2013), *Household Vulnerability to Global Financial Crisis and Their Risk Coping Strategies: Evidence from Nine Rural Villages in Cambodia*

78) Tong Kimsun and Phay Sokcheng (March 2013), *The Role of Income Diversification during the Global Financial Crisis: Evidence from Nine Villages in Cambodia*

79) Lun Pidé (March 2013), *The Role of Rural Credit during the Global Financial Crisis: Evidence From Nine Villages in Cambodia*

80) Saing Chan Hang (March 2013), *Binding Constraints on Economic Growth in Cambodia: A Growth Diagnostic Approach*